# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤១៧ ព្រទ-២០០១

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើជូន**

**ឯកឧត្តមប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល**
**លោកជំទាវចៅក្រមប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**
**លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីសាលក្រម សាលដីកា និងសេចក្តីសម្រេចផ្សេងៗរបស់ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលជាស្ថាពរ មានអានុភាពយកទៅអនុវត្តលើជនល្មើសជាមន្ត្រីរាជការ ។

**យោង:** លិខិតលេខ១៨៤៤-អយក-បល ចុះថ្ងៃទី០៦-០៧-២០០១ របស់ក្រសួងអប់រំយុវជន និងកីឡា ។

កន្លងមកតុលាការខេត្ត-ក្រុង មួយចំនួនបានទទួលដោះស្រាយសំណុំរឿងក្តីពាក់ព័ន្ធនឹងជនល្មើសជាមន្ត្រីរាជការ ហើយអស់លោកបានសុំអនុញ្ញាតចោទប្រកាន់ ឬជូនដំណឹងពីការផ្តើមចោទប្រកាន់ ឬពីការឃុំខ្លួនជនជាប់សង្ស័យជាមន្ត្រីរាជការទាំងនោះទៅប្រធានស្ថាប័នសាមីតាមច្បាប់កំណត់រួចហើយ ប៉ុន្តែក្រោយពីដោះស្រាយសំណុំរឿងទាំងនេះចប់សព្វគ្រប់អស់លោកពុំបានយកចិត្តទុកដាក់ចាត់បញ្ជូនសាលក្រម សាលដីកាស្ថាពរ ឬសេចក្តីសម្រេចផ្សេងៗ ដែលមានទាក់ទងជាមួយមន្ត្រីរាជការទាំងនោះទៅប្រធានស្ថាប័នសាមី ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់នៅឡើយទេ ។

ថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា បានសំណូមពរមកក្រសួងយុត្តិធម៌តាមលិខិតលេខៈ១៨៤៤-អយក-បល ចុះថ្ងៃទី០៦-០៧-២០០១ សុំឱ្យក្រសួងយុត្តិធម៌ជួយអន្តរាគមន៍ទៅតុលាការគ្រប់ជាន់ថ្នាក់ដែលទទួលដោះស្រាយសំណុំរឿងក្តីព្រហ្មទណ្ឌ ដែលមានពាក់ព័ន្ធនឹងមន្ត្រីរាជការរបស់ក្រសួងអប់រំ យុវជន និងកីឡា ជួយឱ្យចាត់បញ្ជូនសាលក្រមឬសាលដីកាស្ថាពរទៅប្រធានស្ថាប័ននេះបានជ្រាបជាព័ត៌មានវិញផង ដើម្បីស្ថាប័នសាមីអាចមានលទ្ធភាពចាត់វិធានការអនុវត្តទៅលើមន្ត្រីរាជការរូបនោះ ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។

ផ្អែកតាមសំណូមពរនេះ ខ្ញុំសូមឯកឧត្តម លោកជំទាវ អស់លោកជួយចាត់ឱ្យសើរើពិនិត្យមើលឱ្យបានល្អិតល្អន់ និងហ្មត់ចត់នូវសាលក្រម សាលីកា និងសេចក្តីសម្រេចផ្សេងៗដែលមានពាក់ព័ន្ធនឹងមន្ត្រីរាជកា ហើយដែលមានអានុភាពអនុវត្តតាមច្បាប់ពេញលេញហើយនោះផ្ញើជូនទៅប្រធានស្ថាប័នសាមី ដើម្បីយកទៅអនុវត្តតាមច្បាប់ ។ ដូច្នេះអំណើះតទៅរាល់សំណុំរឿងព្រហ្មទណ្ឌដែលមានពាក់ព័ន្ធនឹងមន្ត្រីរាជការ ដែលអស់លោកទទួលបន្ទុកដោះស្រាយដោយបានជូនដំណឹងពីការផ្តើមចោទប្រកាន់ ឬពីការឃុំខ្លួនបណ្តោះអាសន្នទៅប្រធានស្ថាប័នសាមីតាមមាត្រា ៥១ថ្មី នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលរួចហើយ នៅពេលរឿងក្តីនេះដោះស្រាយតាមផ្លូវតុលាការចប់សព្វគ្រប់ចាំបាច់អស់លោកត្រូវចាត់បញ្ជូនសាលក្រម សាលដីកាស្ថាពរ ឬសេចក្តីសម្រេចផ្សេងៗដែលមានអានុភាពអនុវត្តតាមច្បាប់ពេញលេញហើយនោះទៅបធានស្ថាប័នសាមីទាំងនោះកុំបីខាន ដើម្បីស្ថាប័នសាមីបានយកទៅអនុវត្តបន្តតាមច្បាប់កំណត់ ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តម លោកជំទាវ អស់លោកជាប្រធានតុលាការគ្រប់ជាន់ថ្នាក់ជួយប្រជុំផ្សព្វផ្សាយលស់ ចៅក្រមក្រោមឱវាទ ឱ្យយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**ឆាង ស៊ីថុង**

<u>ចម្លងជូន</u>

-ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីជ្រាប